ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍កិច្ចប្រជុំ

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី ៤ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥

រៀបចំដោយ: នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ: ថវិកាជាតិ

## ១. សេចក្ដីផ្ដើម:

យោងទៅតាមអណត្តិដែលមានចែងក្នុងទស្សន:វិស្ស័យ បេសកកម្មដែលកំណត់ដោយច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងអនុក្រឹត្យស្ដីពីការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**មាត្រា១៨**- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានក្រុមប្រឹក្សាបច្ចេកទេសមួយជាជំនួយការ ដែលមានសមាជិកជាមន្ត្រីដែលចាត់តាំងដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**មាត្រា១៨**- ក្រុមប្រឹក្សាបច្ចេកទេស នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ ក្រោមការដឹកនាំកិច្ចប្រជុំដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីៈ

- រៀបចំគោលនយោបាយប្រយុទ្ធនឹងជំងឺអេដស៍ ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលនយោបាយប្រយុទ្ធនឹងជំងឺអេដស៍ ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- រៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍
- ជួយណែនាំការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនិងតម្រូវការនៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍។
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រគល់ជូន។

ហេតុនេះហើយទើបនៅព្រឹកថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៥ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី ៤ សម្រាប់ខែមិនានិងមេសា ឆ្នាំ ២០១៥ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ២៩ ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ។

កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ ។

## ២. គោលបំណងនៃកិច្ចប្រជុំ

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធិផល និងទិសដៅបន្ត ក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សំរបសំរួលការងារបច្ចេកទេស តាមរបៀបវារ: ដូចខាងក្រោមៈ

- របាយការណ៍សង្ខេបប្រចាំខែមិនានិងមេសា របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ការបង្ហាញពីបច្ចុប្បន្នភាព និងបញ្ហាប្រឈម ចំពោះអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ នៅភូមិរកា ឃុំរការ ស្រុកសង្កែ ខេត្តបាត់ដំបង ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

- និងបញ្ហាផ្សេងៗ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម វេជ្ជបណ្ឌិត តៃង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

<u>**ប្រធានបទទី១**</u>. **ឯកឧត្តម វេជ្ជបណ្ឌិត ខា ម៉ៅ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជំរាបជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើក្នុងខែមីនា និងមេសា ដូចខាងក្រោម៖

- នាថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ឯកឧត្តមទេសរដ្ឋមន្ត្រី**អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានគណៈកម្មាធិការសំរបសំរួលមូលនិធិសកលប្រចាំប្រទេសកម្ពុជា (CCC) បានអញ្ជើញជាអធិបតីនៅក្នុងកិច្ចប្រជុំពិសេសគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការសម្របសម្រួលមូលនិធិសកល ប្រចាំប្រទេសកម្ពុជានៅទីស្នាក់ការកណ្តាលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

- ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ បានប្រារព្ធទិវានារីអន្តរជាតិ ៨ មីនាខួបលើកទី១០៤ ក្រោមប្រធានបទ ដំណើរឆ្ពោះទៅមុខស្ត្រីកម្ពុជាក្រោយសន្និសិទ្ធស្ត្រីពិភពលោកឆ្នាំ១៩៩៥ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ចូលរួមកិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិក្នុងការអនុវត្តន៍កម្មវិធីបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅខេត្តសៀមរាប ដែលរៀបចំដោយអង្គការ MHC។

- ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ចូលរួមកិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិក្នុងការអនុវត្តន៍កម្មវិធីបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ របស់កម្មវិធីMStyle នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

- ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំត្រីមាសទីមួយនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរសនិងស្រីស្រស់នៅសណ្ឋាគារ Raffles Hotel Le Royal។

- ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំអន្តរក្រសួង ដោយមានការចូលរួមពីតំណាងក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។

- ថ្ងៃទី២៦ ដល់ទី២៨ ខែមីនា ឆ្នាំ២០១៥ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀប ចំពិធីវិបស្សនា(Retreat) នៅក្រុងកែប។

➢ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ចូលរួមក្នុងកម្មវិធីយុទ្ធនាការប្រឆាំងការមាក់ងាយ និងការរើសអើង ក្រុមបុរសស្រឡាញ់បុរស ស្រីស្រស់ នៅខេត្តសៀមរាប។

➢ នៅពេលព្រឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

➢ នៅពេលរសៀលថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលអំពីមេរោគអេដស៍ និងជំងឺអេដស៍។

➢ ការរៀបចំគម្រោងផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៤ ឆ្នាំ២០១៦-២០២០ (NSPIV)។

➢ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៥ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** បានចូលរួមបើកសិក្ខាសាលាថ្នាក់ជាតិផ្ទៀងផ្ទាត់លទ្ធផលនៃការរៀបចំរបាយការណ៍សកល នៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍(GARPR) នៅប្រទេសកម្ពុជា។

➢ ថ្ងៃទី២៣-២៥ ខែមេសា ឆ្នាំ២០១៥ ចុះបេសកកម្មពិនិត្យស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង។

❖ **ផែនការសកម្មភាព និងទិសដៅបន្ត**

- បន្តធ្វើកិច្ចការ NSPIV ផ្នែកLog Frame
- រៀបចំសិក្ខាសាលាសេចក្តីព្រាងបញ្ចប់ NSPIV
- ធ្វើការពិនិត្យទម្រង់បញ្ចូលទិន្នន័យ GARPR
- សម្របសម្រួលជាមួយក្រសួងសង្គមកិច្ច ក្នុងការរៀបចំកម្មវិធីសម្រាប់ចុះអប់រំដល់កុមារកំព្រា និងកុមារដែលងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍។
- ចុះអភិបាលកិច្ច លើការអនុវត្តន៍ការងារឆ្លើយតបទៅនឹងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ នៅតាមបណ្តាខេត្ត។

ក្រោយពីបង្ហាញចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានស្នើអោយបន្ថែមនូវសកម្មភាពដែលក្រុមការងារបានធ្វើកន្លងមក សំរាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

<u>លោក ហេង គួយ</u> **តំណាងអង្គការ HACC:** បានរៀបចំធ្វើការសិក្សាស្រាវជ្រាវស្តីពី PHIV&ID Poor. ធ្វើសិក្ខាសាលាប្រមូលថវិកាសំរាប់ជួយប្រជាពលរដ្ឋនៅភូមិរកា ដោយប្រមូលថវិកា និងសម្ភារ:ជាង ២០០០ដុល្លា អាមេរិក។ ចុះសួរសុខទុក្ខ និងចែកអំណោយជូនប្រជាពលរដ្ឋរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍។

<u>លោក ឡុង ឡារី</u> ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ: មានការផ្លាស់ប្តូរប្រធានគណ:កម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញពី**លោកជំទាវ ម៉ក់ ស៊ីវណ្ណថា ទៅឯកឧត្តម ប៊ុនសេរី** និងមានការកែសំរួលគណ:កម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខណ្ឌទាំង១២។ រហូតមកដល់ពេលនេះ PAC PAS CAC DAC ពុំទាន់បានប្រជុំនៅឡើយដោយពុំទាន់បានទទួលថវិកា

ពីថ្នាក់ជាតិ។ សំណូមពរអោយអង្គការសង្គមស៊ីវិលទាំងអស់ក្នុងរាជធានីភ្នំពេញ ចុះMoU ជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ ដើម្បីងាយស្រួលក្នុងការសម្របសម្រួល ការអនុវត្តសកម្មភាព។

__ប្រធានបទទី២.__ ការបង្ហាញពីបច្ចុប្បន្នភាព និងបញ្ហាប្រឈម ចំពោះអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ នៅភូមិរកា ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង ដោយលោកវេជ្ជបណ្ឌិត **ឡាន វណ្ណសេង** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគៈ គំនិតផ្តួចផ្តើមកម្ពុជា ៣.០ ដោយផ្តោតទៅលើការបែងចែក១០ឆ្នាំ ក្នុងមួយដំណាក់កាល។

- ដំណាក់កាលទី១៖ ១៩៩១-២០០០ ដោយផ្តោតទៅលើការអប់រំ និងការងារបង្ការទៅលើស្ត្រីបំរើសេវាកំសាន្តសប្បាយ។
- ដំណាក់កាលទី២៖ ២០០១-២០១០ ដោយផ្តោតទៅលើអប់រំប្រជាពលរដ្ឋទូទៅ ព្រមទាំងការព្យាបាល និងថែទាំដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។
- ដំណាក់កាលទី៣៖ ២០១១-២០២០ (ដំណាក់កាល៣.០) ចង់អោយកម្ពុជា គ្មានការចំលងថ្មីនៅឆ្នាំ ២០២០ ត្រូវមានការចូលរួមពីគ្រប់ស្ថាប័នពាក់ពន្ធ័ ទើបទទួលបានជោគជ័យ។

ចំពោះស្ថានភាព និងការផ្ទុះឡើងនៃមេរោគអេដស៍ក្នុងឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង រហូតមកដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ លទ្ធផលវិជ្ជមានអ្នកដែលមកធ្វើតេស្តឈាមរកមេរោគអេដស៍ បានកើនដល់ចំនួន២៥០នាក់ ក្នុងនោះ១៦៨នាក់ បានទទួលថ្នាំប្រឆាំងមេរោគអេដស៍ ។

បន្ទាប់មកក្រសួងសុខាភិបាល បានអន្តរាគមន៍ជាបន្តបន្ទាប់ដូចតទៅ ៖

- ផ្តល់វិធានការណ៍លើកទឹកចិត្ត ទប់ស្កាត់ការរើសអើង និងព័ត៌មានអវិជ្ជមានផ្សេងៗ។
- រៀបចំក្រុមគ្រូពេទ្យចុះព្យាបាលអ្នកជំងឺអេដស៍ដល់មូលដ្ឋាន និងរៀបចំប្រព័ន្ធបញ្ជូន អ្នកជំងឺ ក្នុងករណីធ្ងន់ធ្ងរ។
- ក្រសួងបានផ្តល់នូវអគារពីរជាន់ ចំនួនមួយ និងរៀបចំជាកន្លែងសំរាកព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នឹងផ្តល់គ្រូពេទ្យសំរាប់ទទួលខុសត្រូវក្នុងការថែទាំ និងព្យាបាល។
- ក្រសួងបានផ្តល់រថយន្តសង្គ្រោះមួយគ្រឿង ដើម្បីបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរ។
- ក្រសួងកិច្ចកានារីនឹងផ្តល់ការអប់រំបន្តដល់ស្ត្រីមេផ្ទះនិងអាហារូបត្ថម្ភ ។
- ក្រសួងសង្គមកិច្ចជួយក្មេងអោយបានចូលរៀន។
- កាំកបាទក្រហមជួយអណ្តូងទឹក១២ (១ភូមិមាន២) និងសង់បង្គន់លើសពី១០០។
- ក្រសួងធនធានទឹក និងសប្បរសជនជួយជីកស្រះទឹក ២។
- អង្គកាខាណា(KHANA) ជួយស្តារប្រឡាយ២ខ្សែ។

ក្រោយពីបង្ហាញចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានសំណូមពរដល់អង្គការ HACC ត្រូវមានតំណាងមកចូលរួមប្រជុំជាប្រចាំ ជាពិសេសបណ្តាញក្រុមទាំង៣។

បន្ទាប់មកឯកឧត្តម បានជូនដំណឹងដល់សមាជិកអង្គប្រជុំថា សំរាប់កិច្ចប្រជុំលើកទី៥ នឹងប្រព្រឹត្តទៅ នៅ **<u>ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៥</u>**តាមរបៀបវារៈដូចខាងក្រោម៖

១. របាយការណ៍សង្ខេបប្រចាំខែឧសភា របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. ការបង្ហាញពីបច្ចុប្បន្នភាព និងបញ្ហាប្រឈម ចំពោះស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅរាជធានីភ្នំពេញ។

៣. បញ្ហាផ្សេងៗ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង១៥នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

**<u>ឧបសម្ព័ន្ធ</u>**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៥

អ្នករៀបចំរបាយការណ៍

វេជ្ជ. ហេង ហៃ

បានឃើញ និងឯកភាព

**អគ្គលេខាធិការ**

វេជ្ជ. តែង គន្ធី